**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី៣ ឆ្នាំ២០២១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សេចក្តីផ្តើម**:

ឆ្នាំ២០២១ គឺជាឆ្នាំទី៦ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ "ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចិរភាព"។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធីនិងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២១អង្គភាពថវិកានិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានីខេត្ត។

## I-**ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១**

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានគ្រោងឥណទានចំណាយថវិកា ឆ្នាំ២០២១ សរុបមានចំនួន ២៧៧ ៥៥៣ លានរៀល ក្នុងនោះ ៖

**(ក) រដ្ឋបាលកណ្តាល**៖ បានគ្រោងឥណទានចំណាយថវិកាសរុបចំនួន ១៨០ ២៧៧ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៦៤ ២៧៧ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ១៦ ០០០ លានរៀល

**(ខ) មន្ទីររាជធានី ខេត្ត** ៖បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន ៩៧ ២៧៦ លានរៀល

## II-**លទ្ធផលសម្រេចបាន**

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នៅក្នុងត្រីមាសទី៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុវត្តចំណាយ តាមអាណត្តិបើកប្រាក់សរុបចំនួន៥៩ ៥១៥,៨ លានរៀល ស្មើនឹង២១,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបានចំនួន៣៦ ៩៥៦,៥លានរៀលស្មើនឹង២០,៥%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៧៤,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ។ រីឯមន្ទីររាជធានី ខេត្តអនុវត្តបានចំនួន ២២ ៥៥៩,៣លានរៀល ស្មើនឹង២៣,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៦៩,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

**(ក) រដ្ឋបាលកណ្តាល**៖

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់

របស់រដ្ឋបាលកណ្តាល(២១អង្គភាពថវិកា) សម្រេចបានចំនួន៣៦ ៩៥៦,៥លានរៀលក្នុងនោះ (១)ចំណាយចរន្តអនុវត្តបាន៣២ ៩៤៥ លានរៀលស្មើនឹង២០,១%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៦៦,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ក)ការទិញ(ជំពូក៦០) អនុវត្តបានចំនួន៦ ៥៥៣,៥ លានរៀល ស្មើនឹង២៧,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៧៣,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៣ ១៩៨,៣ លានរៀលស្មើនឹង៧,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង២៣,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ) បន្ទុកបុគ្គលិក(ជំពូក៦៤) អនុវត្តបានចំនួន១៦ ៦៨០,៧ លានរៀល ស្មើនឹង២៣,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៧៨,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន៦ ៤២៥,៥លានរៀល ស្មើនឹង២៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១១៤,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២) ចំណាយមូលធនអនុវត្តបាន៤ ០១១,៥ លានរៀល ស្មើនឹង២៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១។

ម្យ៉ាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ឃើញថាទឹកប្រាក់សរុបចំនួន៣៦ ៩៥៦,៥លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់៖

(១) បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម និងកសិធុរកិច្ច (កម្មវិធីទី១) ចំនួន៨ ៥៥២,៧ លានរៀល ស្មើនឹង១៩,៦%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(២) ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ ( កម្មវិធីទី២) ចំនួន៤ ២៦៨,៩ លានរៀល ស្មើនឹង៣២,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(៣) គ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន២ ០០០,៦ លានរៀល ស្មើនឹង១៤,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(៤) គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ (កម្មវិធីទី៤) ចំនួន ៦៥៥,៦លានរៀល ស្មើនឹង៦,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

(៥) បង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស(កម្មវិធីទី៥) ចំនួន២១ ៤៧៨,៨លានរៀល ស្មើនឹង២១,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

**(ខ) មន្ទីររាជធានី ខេត្ត ៖**

ផ្អែកតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ឃើញថាមន្ទីរកសិកម្ម រុក្ខាប្រមាញ់និង នេសាទទាំង២៥រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន ២២ ៥៥៩,៣ លានរៀលក្នុងនោះចំណាយលើ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន១ ៧៥៤,៨ លានរៀល ស្មើនឹង១៥,៦ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៥៤,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៥ ៧០២,៩ លានរៀលស្មើនឹង២៥,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៥៤,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ) បន្ទុកបុគ្គលិក (ជំពូក៦៤ ) អនុវត្តបានចំនួន១៣ ៦៥០,៤ លានរៀល ស្មើនឹង២៤,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៨៣,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) អត្ថប្រយោជន៍សង្គម (ជំពូក៦២) អនុវត្តបានចំនួន១ ៤៣៣, ៩លានរៀល ស្មើនឹង១៩,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៥៦,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) អនុវត្តបានចំនួន១៧,៣លានរៀល ស្មើនឹង២២,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១។

ម្យ៉ាងទៀតពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុប ចំនួន ២២ ៥៥៩,៣ លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តដូចខាងក្រោម៖

ឯកតា: រៀល

| មន្ទីររាជធានីខេត្ត | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ | ការអនុវត្តត្រីមាសទី៣ | %ធៀបច្បាប់ហិរញ្ញវត្ថុ២០២១ | %ធៀបកម្មវិធីត្រីមាសទី៣ |
|---|---|---|---|---|
| បន្ទាយមានជ័យ | 3 711 100 000 | 883 472 130 | 23.8% | 105.9% |
| បាត់ដំបង | 6 489 100 000 | 1 391  427 456 | 21.4% | 89.4% |
| កំពង់ចាម | 3 949 300 000 | 596 412 381 | 15.1% | 56% |
| កំពង់ឆ្នាំង | 3 878 800 000 | 820 962600 | 21.2% | 90.3% |
| កំពង់ស្ពឺ | 4 923 900 000 | 1 441 587 480 | 29.3% | 101.4% |
| កំពង់ធំ | 5 497 900 000 | 1 887 626 655 | 34.3% | 76.4% |
| កំពត | 3 999 000 000 | 657 470 300 | 16.4% | 43.7% |
| កណ្តាល | 6 180 000 000 | 1 624 422 320 | 26.3% | 86.9% |
| កោះកុង | 2 498 100 000 | 421 957 940 | 16.9% | 79.9% |
| ក្រចេះ | 3 903 800 000 | 873 711 923 | 22.4% | 72.8% |
| មណ្ឌលគិរី | 2 898 400 000 | 899 538 080 | 31% | 64.3% |
| រាជធានីភ្នំពេញ | 4 333 100 000 | 1 006 231 750 | 23.2% | 54.7% |
| ព្រះវិហារ | 2 924 700 000 | 885 697 940 | 30.3% | 47.6% |
| ព្រៃវែង | 4 515 000 000 | 801 210 016 | 17.8% | 79.5% |
| ពោធិ៍សាត់ | 3 875 200 000 | 555 043 910 | 14.3% | 30.5% |
| រតនគិរី | 3 080 700 000 | 522 806 300 | 16.9% | 128.9% |
| សៀមរាប | 5 712 400 000 | 1 057 842 600 | 18.5% | 38.1% |
| ព្រះសីហនុ | 2 887 000 000 | 754 912 570 | 26.2% | 52.9% |
| ស្ទឹងត្រែង | 3 270 000 000 | 706 492 852 | 21.6% | 82% |
| ស្វាយរៀង | 2 894 700 000 | 781 472 550 | 27% | 111.8% |
| តាកែវ | 5 153 600 000 | 1 919 162 491 | 37.2% | 100.1% |
| ឧត្តរមានជ័យ | 3 007 100 000 | 506 880 600 | 16.9% | 74.5% |
| កែប | 1 717 500 000 | 330 489 960 | 19.2% | 60.9% |
| ប៉ៃលិន | 2 285 800 000 | 570 948 986 | 24.9% | 105.5% |
| ត្បូងឃ្មុំ | 3 689 800 000 | 661 543 589 | 17.9% | 43% |

## III-បញ្ហាប្រឈម

យោងតាមការអធិប្បាយខាងលើឃើញថា ការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី៣ឆ្នាំ២០២១ សម្រេចបានទាបជាងឆ្នាំ២០២០ក្នុងរយៈពេលដូចគ្នា ដោយសារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកែសម្រួលនីតិវិធីមួយចំនួនដើម្បីឆ្លើយតបនឹងការផ្ទុះជម្ងឺឆ្លងធ្ងន់ធ្ងរកូវីដ-១៩ តាមរយៈការចេញនូវប្រកាសណែនាំស្តីពីនីតិវិធីថ្មីៗពាក់ព័ន្ធការចំណាយរដ្ឋទេយបុរេប្រទាន ការចំណាយប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស ការចំណាយរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា សន្និសិទ និងកិច្ចប្រជុំផ្សេងៗ ។ ការងារនេះតម្រូវឲ្យអង្គភាពថវិកានីមួយៗសិក្សាស្វែងយល់ឲ្យបានច្បាស់លាស់ និងត្រូវរៀបចំឯកសារពាក់ព័ន្ធមួយចំនួនទំរាំអាចអនុវត្តការចំណាយបាន។

ទន្ទឹមនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួបបញ្ហាប្រឈមមួយចំនួនដែលធ្វើឲ្យដំណើរការចំណាយមានការយឺតយ៉ាវខ្លះៗ ទាំងចំណាយចរន្តនិងចំណាយមូលធនដែលបញ្ហាលំបាកទាំងនោះមានដូចជា៖

-ការផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភាពយឺតយ៉ាវដែលនាំឲ្យរាំងស្ទះដល់ការងារអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ(ទាំងថវិកាចរន្តនិងមូលធន)។

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនទាន់ចេញបទដ្ឋានគតិយុត្តពាក់ព័ន្ធចំណាយតាមនីតិវិធីទូទាត់ត្រង់ ដែលផ្ទេរពីចំណាយរដ្ឋទេយ្យបុរេប្រទាន

-ឯកសារគាំទ្រសម្រាប់ជម្រះទូទាត់រដ្ឋទេយ្យបុរេប្រទានរបស់អង្គភាពថវិកាមួយចំនួន មិនទាន់បំពេញបានគ្រប់គ្រាន់និងទាន់ពេលវេលា។

## IV-ទិសដៅអនុវត្តបន្ត

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាកររបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី៤ឆ្នាំ២០២១ ដែលមានទឹកប្រាក់សរុបចំនួន ១១១ ១៦៨ ៣២៤ ០០០រៀល ក្នុងនោះរួមមាន ៖

ឯកតា: រៀល

| ចំណាត់ថ្នាក់សេដ្ឋកិច្ច | រដ្ឋបាលកណ្តាល | មន្ទីររាជធានី ខេត្ត |
|---|---|---|
| ជំពូក ៦០ (ការទិញ) | 12 419 300 000 | 2 294 348 000 |
| ជំពូក ៦១ (សេវាកម្ម) | 39 811 800 000 | 10 731 019 000 |
| ជំពូក ៦៤ (បន្ទុកបុគ្គលិក) | 20 838 100 000 | 16 742 271 000 |
| ជំពូក៦២(អត្ថប្រយោជន៍សង្គម) | 4 000 000 | 1 105 385 000 |
| ជំពូក ៦៥ (ឧបត្ថម្ភធន) | 6 955 800 000 | |
| ជំពូក ៦៣ (ពន្ធនិងអាករ) | 205 200 000 | 61 100 000 |
| **សរុប** | **80 234 200 000** | **30 934 124 000** |

## V-សេចក្តីសន្និដ្ឋាន

ឆ្លងតាមការពិនិត្យវាយតម្លៃការអនុវត្តចំណាយថវិកា ប្រចាំត្រីមាសទី៣ របស់អង្គភាពនៃរដ្ឋបាលកណ្តាល ជារួមសម្រេចបាន៧៤,៥% នៃកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះបានមកដោយសារការចំណាយឧបត្ថម្ភធន(ជំពូក៦៥)អនុវត្តបានលើសកម្មវិធីដែលបានដាក់ចេញប្រមាណ១៤,៣% ការចំណាយជំពូក២១អនុវត្តបាន២៥%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ រីឯការចំណាយលើការទិញ(ជំពូក៦០) បន្ទុកបុគ្គលិក(ជំពូក៦៤) អត្ថប្រយោជន៍សង្គម(ជំពូក៦២)អនុវត្តបានល្អបង្គួរធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ដោយឡែកការចំណាយសេវាកម្ម(ជំពូក៦១)អនុវត្តបានទាបខ្លាំងគឺដោយសារ(១)ដំណើរការទូទាត់ចំណាយតាមនីតិវិធីលទ្ធកម្ម ក្នុងកំឡុងពេលនេះមិនទាន់ចប់រួចរាល់ (២) ការទូទាត់ចំណាយបុរេប្រទាន និងរដ្ឋទេយ្យបុរេប្រទានមានតិចតួច ដោយសារមានការកែសម្រួលនីតិវិធីអនុវត្តទន្ទឹមនេះការចំណាយទូទាត់ត្រង់ដែលទទួលបានធានាចំណាយហើយ ត្រូវជួបការលំបាកស្មុគស្មាញក្នុងការលើកសំណើរទូទាត់ជម្រះ ដោយសារភាពមិនច្បាស់លាស់ និងមិនទាន់មានបទដ្ឋានគតិយុត្តចែងពាក់ព័ន្ធនីតិវិធីទូទាត់ត្រង់នេះ។

ចំពោះការអនុវត្តចំណាយថវិការបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមសម្រេចបានបង្គួរ ក្នុងកម្រិត៦៩,១%នៃកម្មវិធីដែលបានដាក់ចេញ។ ទោះបីជាយ៉ាងនេះក្តី មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តចំនួនបីគឺខេត្តពោធិ៍សាត់ ត្បូងឃ្មុំនិងខេត្តកំពតអនុវត្តចំណាយថវិកាបានទាបដែលត្រូវធ្វើការជំរុញនិងកែលម្អបន្ថែមទៀត។

សរុបសេចក្តីមក ការអនុវត្តចំណាយថវិកា តាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមនៅតែទទួលបានលទ្ធផលល្អ ទោះបីជាមានការកែសម្រួលនីតិវិធីមួយចំនួននិងធ្វើឲ្យការអនុវត្ត

ចំណាយលើការទិញនិងចំណាយសេវាកម្មអនុវត្តបានទាបក្តី ។ ការចំណាយប្រភេទនេះនឹងកើនឡើងក្នុងត្រីមាសបន្ទាប់ ប្រសិនបើស្ថានភាពនៃការឆ្លងជម្ងឺកូវីដ-១៩ បានធូរស្រាលគួបផ្សំនឹងបែបបទ នីតិវិធីពាក់ព័ន្ធចំណាយត្រូវបានរៀបចំបំពេញរួចរាល់។

ថ្ងៃពុធ ១៤កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១

**រដ្ឋលេខាធិការនិងជាអនុប្រធានក្រុមការងាររៀបចំថវិកា**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**